# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងពាណិជ្ជកម្ម**
លេខ ៣៤៥៣ ព.ណ.ក.ស.ម

ថ្ងៃព្រហស្បតិ៍ ១កើត ខែមិគសិរ ឆ្នាំខាលចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែវិច្ឆិកា ឆ្នាំ ២០២២

## ជម្រាបមក
### លោក/លោកស្រីប្រធានក្រុមហ៊ុន អារណាម (ខេមបូឌា) ខមភេនី លីមីធីត

**កម្មវត្ថុ:** ការកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលទឹកផ្លែឈើ និងទឹកស៊ីរ៉ូម៉ាក "TEISSEIRE" របស់ក្រុមហ៊ុន **អារណាម (ខេមបូឌា) ខមភេនី លីមីធីត** ក្នុងព្រះរាជាណាចក្រកម្ពុជា។

**យោង:**- មាត្រា ៣ និងមាត្រា ១១នៃច្បាប់ស្តីពី ម៉ាក ពាណិជ្ជនាម និងអំពើនៃការប្រកួតប្រជែងមិនស្មោះត្រង់
- លិខិតស្នើសុំរបស់ក្រុមហ៊ុន **អារណាម (ខេមបូឌា) ខមភេនី លីមីធីត** ចុះថ្ងៃទី ២៧ ខែកញ្ញា ឆ្នាំ ២០២២
- លិខិតប្រគល់សិទ្ធិផ្តាច់មុខរបស់ក្រុមហ៊ុន Teisseire France, Société par actions simplifiée ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ ២០២២
- វិញ្ញាបនបត្រចុះបញ្ជីម៉ាកសាជាថ្មី លេខចុះបញ្ជី KH/៤០៨៧៨/១២ ចុះថ្ងៃទី ០២ ខែវិច្ឆិកា ឆ្នាំ ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបលោក/លោកស្រីប្រធានថា ក្រសួងពាណិជ្ជកម្មឯកភាពកត់ត្រាទទួលស្គាល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខលើផលិតផលទឹកផ្លែឈើ និងទឹកស៊ីរ៉ូពាក់ម៉ាកខាងលើរបស់ក្រុមហ៊ុន **អារណាម (ខេមបូឌា) ខមភេនី លីមីធីត** ក្នុងព្រះរាជាណាចក្រកម្ពុជា ដែលទទួលបានពីក្រុមហ៊ុន Teisseire France, Société par actions simplifiée ដូចមានចែងក្នុងលិខិតប្រគល់សិទ្ធិនាំចូល និងចែកចាយផ្តាច់មុខដែលក្រសួងបានតម្កល់ទុករួចហើយ។

លិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះមានសុពលភាព ០២(ពីរ) ឆ្នាំ ដោយគិតចាប់ពីថ្ងៃចុះហត្ថលេខា ហើយអាចនឹងត្រូវបាត់បង់សុពលភាពជាស្វ័យប្រវត្តិមុនកាលបរិច្ឆេទផុតកំណត់ខាងលើ ប្រសិនបើមានការជូនដំណឹងអំពីការបញ្ចប់សិទ្ធិពីក្រុមហ៊ុន Teisseire France, Société par actions simplifiée ដែលជាម្ចាស់ម៉ាក។

ចាប់ពីក្រោយរយៈពេល ៩០(កៅសិប)ថ្ងៃ គិតចាប់ពីថ្ងៃចុះហត្ថលេខាលើលិខិតកត់ត្រានិងតម្កល់សិទ្ធិផ្តាច់មុខនេះអ្នកទទួលសិទ្ធិស្របច្បាប់មានសិទ្ធិប្តឹងទៅអាជ្ញាធរមានសមត្ថកិច្ច ដើម្បីចាត់វិធានការរារាំងទំនិញដែលនាំចូលស្របគ្នា។

នីតិបុគ្គលដែលទទួលបានសិទ្ធិនាំចូល និងចែកចាយផ្តាច់មុខ ត្រូវផ្សព្វផ្សាយលិខិតខាងលើនេះជាបន្ទាន់ក្នុងទំព័រខាងមុខរបស់សារព័ត៌មានក្នុងព្រះរាជាណាចក្រកម្ពុជា និងបណ្តាញសង្គមនានា និងត្រូវអនុវត្តឱ្យបានត្រឹមត្រូវតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

អាស្រ័យហេតុនេះ សូមលោក/លោកស្រីប្រធានក្រុមហ៊ុន ជ្រាបជាព័ត៌មាន ។

**ជ.រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**
**រដ្ឋលេខាធិការ**

**អ៊ឹក-ប្រជា**

*__ចម្លងជូន:__*
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ **សម្តេចអគ្គមហាសេនាបតីតេជោ** នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យ សម្តេចក្រឡាហោម **ស ខេង***
- *ខុទ្ទកាល័យ ឯកឧត្តមកិត្តិនីតិកោសលបណ្ឌិត ឧបនាយករដ្ឋមន្ត្រីប្រចាំការ*
- *ខុទ្ទកាល័យ ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
- *អគ្គនាយកដ្ឋានការពារអ្នកប្រើប្រាស់ កិច្ចការប្រកួតប្រជែង និងបង្ក្រាបការក្លែងបន្លំ (ក.ប.ប)*
- *អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា*
- *អគ្គនាយកដ្ឋានពន្ធដារ*
- *ឯកសារ - កាលប្បវត្តិ*

ឡូត៍លេខ ១៩-៦១ មហាវិថីសហព័ន្ធរុស្ស៊ី ភូមិទឹកថ្លា សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា ទូរស័ព្ទ / ទូរសារ: (៨៥៥)-២៣ ៨៦៦ ៤៦៩
Lot 19-61,Russian Federation Blvd, Phum Teuk Thla, Sangkat Teuk Thla, Khan Sen Sok, Phnom Penh, Kingdom of CAMBODIA Phone/Facsimile: (855)-23 866 469